អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ការបោះពុម្ពផ្សាយ
## យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក លើកទី១

ក្រោមការណែនាំរបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ មន្ត្រីច្បាប់ និងមន្ត្រីប្រឹក្សាមួយក្រុមរបស់អង្គបុរេជំនុំជម្រះ ដោយមានជំនួយពីបុគ្គលិកកម្មសិក្សាផ្នែកច្បាប់ផង បានចងក្រងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក។ ការបោះពុម្ពផ្សាយឯកសារនេះលើកទី១ ជាភាសាអង់គ្លេស និងភាសាបារាំង អាចរកមើលបាននៅលើគេហទំព័ររបស់ អ.វ.ត.ក។

ទោះបីពុំមានចែងលម្អិតនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ដែលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្តី តែពីដំបូងអង្គបុរេជំនុំជម្រះបានដំណើរការដោយអន្លើៗ មុននឹងបំពេញការងារជាអចិន្ត្រៃយ៍នៅរាជធានីភ្នំពេញ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ដោយសារមានបណ្តឹងមួយចំនួនដែលអង្គជំនុំជម្រះនេះត្រូវដោះស្រាយ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ទោះបីភារកិច្ចចម្បងរបស់ខ្លួនដែលត្រូវដោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត ពុំសូវកើតឡើងញឹកញាប់ក្តី តែអង្គជំនុំជម្រះត្រូវដោះស្រាយទៅលើទិដ្ឋភាពនានាផ្នែកនីតិវិធីព្រហ្មទណ្ឌ តាមរយៈបណ្តឹងឧទ្ធរណ៍ ឬសំណើសុំមោឃភាព។

នៅក្នុងសកម្មភាពការងាររបស់ខ្លួនរយៈពេល ១៤ ឆ្នាំមកនេះ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចជាង ២៦០ ដោយដោះស្រាយគ្រប់ដំណាក់កាលទាំងអស់នៃការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ចាប់ពីការបើកកិច្ចស៊ើបសួរបឋម រហូតដល់ពេលបិទបញ្ចប់កិច្ចស៊ើបសួរ។ អង្គជំនុំជម្រះបានពិនិត្យទៅលើផ្នែកចម្រុះ ពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌ និងបញ្ហាសំខាន់ៗ ដូចជា ការឃុំខ្លួនបណ្តោះអាសន្ន ភាពអាចទទួលយកបាន ឬសុពលភាពនៃភស្តុតាង និងទ្រឹស្តីគតិយុត្តិនៃសហឧក្រិដ្ឋកម្មរួម។ អង្គបុរេជំនុំជម្រះបានធ្វើការ

វិភាគអំពីយុត្តាធិការរបស់តុលាការ ក្នុងនាមជាតុលាការពិនិត្យចុងក្រោយនៅដំណាក់កាលស៊ើបអង្កេតក្រោមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួននៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ហើយថ្ងៃនេះ ជាការផ្សព្វផ្សាយអត្ថបទចងក្រងយុត្តិសាស្រ្តលើកទី១ របស់ខ្លួន។

ការបោះពុម្ពផ្សាយយុត្តិសាស្រ្តរបស់អង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក លើកទី១ មាននៅក្នុងតំណភ្ជាប់ខាងក្រោម៖

https://eccc.gov.kh/sites/default/files/publications/Jurisprudence%20of%20the%20PTC%20of%20the%20ECCC_EN_FINAL%20%28002%29.pdf

https://eccc.gov.kh/sites/default/files/publications/Recueil%20de%20Jurisprudence%20de%20la%20PTC%20des%20CETC_FR_FINAL.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាអ្នកនាំពាក្យ
ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.phektra@eccc.gov.kh